សួស្តី នៅក្នុងរូបភាពនេះ គឺយើងនឹងនិយាយអំពីការធ្វើឲ្យបែកចានគោម
អញ្ចឹងចានគឺជាសម្ភារៈមួយដែលយើងដាក់នៅផ្ទះបាយ គឺជាសម្ភារៈផ្ទះបាយមួយ
ដែលយើងប្រើប្រាស់សម្រាប់ដាក់បាយ ឬក៏ដាក់ម្ហូប
ឬក៏ប្រើប្រាស់សម្រាប់ធ្វើការងារនៅក្នុងផ្ទះបាយផ្សេងៗ អញ្ចឹងចានគឺមានច្រើនប្រភេទ
គឺដូចជាមានចានសំប៉ែត ចានគោម ឬក៏ចានដែលធ្វើអំពីដែក ចានធ្វើអំពីជ័រជាដើម។
ហើយចានខ្លះទៀត គឺធ្វើអំពីដីឥដ្ឋ ឬក៏ពរ្សឺឡែន អញ្ចឹងចានដែលធ្វើអំពីដី ឬក៏ចានធ្វើអំពីពរ្សឺឡែន
គឺងាយស្រួលនឹងបែកខ្លាំងណាស់ គឺងាយស្រួលនឹងបែក នៅពេលដែលយើងមិនប្រុងប្រយ័ត្ន។

អញ្ចឹងនៅក្នុងរូបភាពទី ១ ដែលនៅក្នុងរូបភាពទី ១ យើងឃើញមានបុរសម្នាក់ ដែលបុរសម្នាក់នោះ
យើងឃើញគាត់មានវ័យប្រហែលជា ២៥ ឆ្នាំ អញ្ចឹងគាត់ពាក់អាវដៃខ្លីពណ៌លឿង
គាត់ពាក់អាវដៃខ្លីពណ៌លឿង ហើយគាត់កំពុងតែឈរនៅក្នុងផ្ទះបាយរបស់គាត់
ដែលគាត់ឈរនៅខាងមុខតុមួយ អញ្ចឹងបុរសម្នាក់នោះ គាត់កំពុងតែកាន់កាំបិត
អញ្ចឹងដៃឆ្វេងរបស់គាត់កាន់កាំបិត ហើយដៃស្តាំគឺកាន់បន្លែដែលជាការ៉ុត
អញ្ចឹងយើងឃើញគាត់កំពុងតែចិតបន្លែនៅក្នុងផ្ទះបាយរបស់គាត់
ដែលយើងឃើញគាត់កំពុងតែហាន់ការ៉ុតជាចំណិតតូចៗដោយប្រើកាំបិតរបស់គាត់
អញ្ចឹងកាំបិតរបស់គាត់ប្រហែលជាមុត ដូច្នេះគាត់អាចចិតបន្លែជាចំណិតតូចៗ
ដូចជាចិតដុំការ៉ុតជាចំណិតតូចៗបានយ៉ាងងាយស្រួល និងបានរហ័ស
ហើយគាត់ប្រហែលជាកំពុងតែធ្វើសម្ល ឬក៏គាត់កំពុងតែធ្វើស៊ុបសម្រាប់អាហារនៅក្នុងថ្ងៃនេះ
ដូច្នេះគាត់យកកាំបិតមកចិតបន្លែ ដោយយើងឃើញនៅក្បែរដៃរបស់គាត់ នៅក្បែរដៃឆ្វេងរបស់គាត់
គឺមានចានគោមមួយដែលមានពណ៌ផ្កាឈូក អញ្ចឹងគាត់ដាក់ចានគោមនៅក្បែរដៃរបស់គាត់
ដែលនៅកែងតុ ឬក៏នៅជ្រុងតុ ហើយគាត់កំពុងតែបន្តចិតបន្លែរបស់គាត់
ដោយយើងឃើញនៅឆ្វេងដៃរបស់គាត់ នៅខាងឆ្វេងដៃរបស់គាត់
យើងឃើញមានបន្លែជាច្រើនផ្សេងទៀត ដែលគាត់ដាក់នៅលើតុសម្រាប់ធ្វើការហាន់
អញ្ចឹងបន្ទាប់ពីគាត់ចិតការ៉ុតមួយនេះហើយ ឬក៏ហាន់ការ៉ុតជាដុំតូចៗហើយ
គាត់នឹងចិតបន្តចិតបន្លែផ្សេងៗទៀតដែលនៅលើតុ ដែលយើងឃើញនៅលើតុ
យើងឃើញមានប៉េងប៉ោះចំនួន ២ យើងឃើញមានខ្ទឹមបារាំង យើងឃើញមានមើមការ៉ុត ១
និងយើងឃើញមានម្ទេសប្លោកផងដែរ។ អញ្ចឹងគាត់ប្រហែលជាកំពុងតែធ្វើម្ហូបសម្រាប់អាហារថ្ងៃនេះ
ឬក៏សម្រាប់អាហារពេលព្រឹក សម្រាប់អាហារពេលល្ងាច ឬក៏សម្រាប់អាហារពេលថ្ងៃត្រង់
អញ្ចឹងគាត់ធ្វើម្ហូបដោយខ្លួនឯង គឺគាត់អត់ទិញពីផ្សារមកទេ ហើយគាត់អត់ប្រើប្រាស់
ឬក៏គាត់អត់មាននរណាម្នាក់ដើម្បីជួយចម្អិនម្ហូបឲ្យគាត់ទេ អញ្ចឹងគាត់ធ្វើម្ហូបខ្លួនឯងដើម្បីញ៉ាំ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ២ នៅក្នុងរូបភាពទី ២ បន្ទាប់ពីគាត់ចិតបានបន្តិចក្រោយមក
អញ្ចឹងគាត់កំពុងតែចិត ប្រើប្រាស់កាំបិតចិតដុំការ៉ុតជាចំណិតតូចៗ
ហាន់ជាចំណិតតូចៗបានបន្តិចក្រោយមក យើងឃើញកែងដៃរបស់គាត់ក៏បានប៉ះទៅនឹងចានគោម
ដែលនៅក្បែរដៃនោះ អញ្ចឹងចានគោមដែលគាត់ដាក់នៅក្បែរនឹងកែងដៃរបស់គាត់
ដែលដាក់នៅនឹងជ្រុងតុ ឬក៏ដាក់នៅនឹងជិតជ្រុងតុ អញ្ចឹងកែងដៃរបស់គាត់បានប៉ះនឹងចានគោម
ដូច្នេះធ្វើឲ្យចានគោមនោះធ្លាក់ពីលើតុ។ អញ្ចឹងនៅក្នុងរូបភាពទី ២ យើងឃើញថា
កែងដៃរបស់គាត់បានប៉ះនឹងចានគោម ហើយចានគោមបានធ្លាក់ពីលើតុចុះមកក្រោម
អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញគាត់បានហាមាត់ អញ្ចឹងគាត់ហាមាត់ធំៗ
និងបើកភ្នែកធំៗសម្លឹងមើលចានគោម បានន័យថាគាត់ភ្ញាក់ផ្អើល ដោយសារតែគាត់ធ្វេសប្រហែស
ធ្វើឲ្យកែងដៃរបស់គាត់ប៉ះចានគោម ធ្វើឲ្យចានគោមធ្លាក់ពីលើតុ
អញ្ចឹងគាត់មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ដែលយើង នៅក្នុងរូបភាពនេះ
គឺយើងឃើញដៃរបស់គាត់កំពុងតែកាន់កាំបិតម្ខាង ហើយដៃម្ខាងទៀតកំពុងតែកាន់ការ៉ុត
ចំណែកឯភ្នែករបស់គាត់និងមាត់របស់គាត់គឺហាមាត់និងបើកភ្នែកធំៗសម្លឹងមើលចានគោម
ដោយសារតែគាត់ភ្ញាក់ផ្អើល ព្រោះតែគាត់ធ្វេសប្រហែស
ធ្វើឲ្យកែងដៃរបស់គាត់ប៉ះចានគោមធ្លាក់ពីលើតុ។

អញ្ចឹងបន្ទាប់មកទៀតនៅក្នុងរូបភាពទី ៣ នៅក្នុងរូបភាពទី ៣ យើងឃើញថា ចានគោមបានធ្លាក់
បង្វិលខ្លួនធ្លាក់ អញ្ចឹងបានន័យថាវាបង្វិលខ្លួនធ្លាក់ពីលើតុចុះមកដល់ក្រោម
ឬក៏ចុះមកដល់កម្រាលឥដ្ឋ អញ្ចឹងយើងឃើញចានគោមនោះបានធ្លាក់ផ្កាប់
អញ្ចឹងយើងឃើញមាត់ចានគោមបានធ្លាក់មកដល់កម្រាលឥដ្ឋមុន ហើយគូទចានគោមគឺនៅខាងលើ
អញ្ចឹងបានន័យថាវាបង្វិលផ្កាប់ អញ្ចឹងនៅពេលដែលវាធ្លាក់គឺវាបង្វិលខ្លួន ហើយផ្កាប់ចុះក្រោម
អញ្ចឹងចានគោមនោះនៅក្នុងរូបភាពទី ៣ បានធ្លាក់ពីលើតុ ធ្លាក់មកដល់កម្រាលឥដ្ឋនៅខាងក្រោម។

បន្ទាប់មកទៀតរូបភាពទី ៤ នៅក្នុងរូបភាពទី ៤ យើងឃើញថា
បន្ទាប់ពីចានគោមដែលធ្លាក់ពីលើចុះមកក្រោម ដែលធ្លាក់ពីលើតុចុះមកក្រោមនោះ
នៅពេលដែលធ្លាក់ប៉ះនឹងកម្រាលឥដ្ឋ ឬរបស់រឹងផ្សេងៗ វានឹងធ្វើឲ្យចានគោមនោះបែក
អញ្ចឹងនៅក្នុងរូបភាពទី ៤ ចានគោមក៏បានបែកបន្ទាប់ពីវាធ្លាក់មកដល់កម្រាលឥដ្ឋ
ដោយសារតែចានគោមនោះធ្វើអំពីព្រឺទ្បេន ដូច្នេះចានដែលធ្វើអំពីព្រឺទ្បេន
គឺងាយស្រួលនឹងបែកណាស់ នៅពេលដែលវាប៉ះទង្គិចទៅនឹងរបស់រឹងផ្សេងៗ
ឬក៏នៅពេលដែលវាធ្លាក់ ដែលជាក់ស្ដែងដូចជាចានគោមអម្បាញ់មិញ
នៅពេលដែលវាធ្លាក់ប៉ះនឹងកម្រាលឥដ្ឋធ្វើឲ្យវាបែក អញ្ចឹងនៅពេលដែលវាបែក

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ជាធម្មតាចានតែងតែមានអំបែង អញ្ចឹងបំណែកតូចៗនៃចានដែលបានបែក យើងហៅថាអំបែង
អញ្ចឹងអំបែងគឺវាមុត អញ្ចឹងនៅពេលដែលយើងប៉ះអំបែងដោយមិនប្រុងប្រយ័ត្ន ឬក៏ដើរជាន់អំបែង
គឺវាអាចធ្វើឲ្យយើងមុតជើងបាន ឬក៏មុតដៃបាន និងធ្វើឲ្យយើងមានគ្រោះថ្នាក់បាន
អញ្ចឹងនៅពេលដែលចានគោមនេះធ្លាក់មកដល់ក្រោម គឺវាបានបែកទៅជាបំណែកតូចៗ
ទៅជាអំបែងចានគោម។

បន្ទាប់មកទៀតរូបភាពទី ៥ រូបភាពទី ៥ បុរសម្នាក់នោះគាត់ក៏បានលើកដៃឡើងទាំងពីរ
ហើយហាមាត់និងបើកភ្នែកធំៗដែលគាត់ភ្ញាក់ផ្អើលខ្លាំង ព្រោះតែគាត់បានធ្វើឲ្យបែកចានគោម
អញ្ចឹងគាត់បានភ្ញាក់ផ្អើល ដោយសារតែគាត់បានធ្វើឲ្យបែកចានគោមរបស់គាត់
ដោយសារតែគាត់ធ្វេសប្រហែស ដូច្នេះធ្វើឲ្យគាត់បើកភ្នែកធំៗ និងហាមាត់ធំៗ
លើកដៃទាំងពីរឡើងលើ ហើយគាត់មានអាការៈភ្ញាក់ផ្អើលយ៉ាងខ្លាំង
ដោយសារតែគាត់ធ្វេសប្រហែសរបស់គាត់ អញ្ចឹងគាត់សោកស្ដាយ
ដោយសារតែគាត់មិនបានប្រុងប្រយ័ត្នឲ្យបានខ្ពស់ ដោយសារតែគាត់រវល់តែចិតបន្លែ
ភ្លេចមើលនៅក្បែរដៃ ធ្វើឲ្យកែងដៃរបស់គាត់ប៉ះទៅនឹងចានគោម និងធ្វើឲ្យចានគោមធ្លាក់បែក។
អញ្ចឹងចានគោមរបស់គាត់ក៏បានធ្លាក់បែក។

បន្ទាប់មកទៀតរូបភាពទី ៦ នៅក្នុងរូបភាពទី ៦ យើងឃើញថា
បន្ទាប់ពីគាត់ឃើញចានគោមរបស់គាត់បែកហើយ បុរសម្នាក់នោះ
គាត់ក៏បានរត់មកក្នុងបន្ទប់ដាក់សម្ភារៈរបស់គាត់ អញ្ចឹងគាត់ក៏បានចេញពីផ្ទះបាយរបស់គាត់
ដែលគាត់ចេញពីផ្ទះបាយរត់មករកបន្ទប់ដាក់សម្ភារៈ ដោយសារតែគាត់ត្រូវការយកអំបោស
ឬក៏យកប្រដាប់កើបសំរាម ដើម្បីទៅប្រមូលអំបែងចេញពីលើកម្រាលឥដ្ឋ
ដែលយើងឃើញនៅក្នុងបន្ទប់ដាក់សម្ភារៈរបស់គាត់ គឺមានសម្ភារៈជាច្រើន ដូចជា
យើងឃើញនៅខាងក្រោម យើងឃើញនៅខាងក្រោមជាប់នៅជញ្ជាំង
យើងឃើញមានម៉ាស៊ីនបូមធូលីចំនួន ១ ដែលម៉ាស៊ីនបូមធូលីនោះ
គឺជាឧបករណ៍សម្រាប់បូមកម្ទេចធូលី ឬក៏បូមសំរាមផ្សេងៗ ដែលប្រើប្រាស់ខ្យល់
អញ្ចឹងវាប្រើខ្យល់បឺតសំរាម ឬក៏ធូលីផ្សេងៗចេញពីកម្រាលឥដ្ឋ
ឬក៏ចេញពីកន្លែងណាមួយដែលយើងចង់សម្អាត អញ្ចឹងគឺជាម៉ាស៊ីនបូមធូលី
ហើយនៅក្បែរម៉ាស៊ីនបូមធូលីគឺមានឈើអំបោសវែង អញ្ចឹងគាត់មានអំបោសវែងមួយ
សម្រាប់បោសផ្ទះ ឬក៏សម្រាប់បោសទីធ្លាផ្ទះរបស់គាត់ ដែលនៅក្បែរឈើអំបោសវែង
គឺយើងឃើញមានដងសម្រាប់ជូតកញ្ចក់ អញ្ចឹងបានន័យថាផ្ដិតទឹក ជាវាជាផ្ដិតទឹកសម្រាប់ជូតកញ្ចក់
អញ្ចឹងនៅពេលដែលយើងចង់ជូតសម្អាតកញ្ចក់របស់យើង យើងប្រើប្រាស់ផ្ដិតទឹកដើម្បីជូតសម្អាត

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ហើយយើងឃើញនៅលើជញ្ជាំងគឺមានបែងចែកចេញជាថ្នាក់ផ្សេងៗផងដែរ ដែលមាន ៣ ថ្នាក់
ដែលយើងឃើញថ្នាក់នៅខាងក្រោម ឬក៏ថ្នាក់ទី ១ យើងឃើញមានធុងចំនួន ២
ដែលជាធុងសម្រាប់ដាក់ទឹក ឬក៏ជាធុងសម្រាប់ដាក់វត្ថុផ្សេងៗផងដែរ អញ្ចឹងមានធុងចំនួន ២
ហើយមានដបថ្នាំ អាចជាថ្នាំលាបផ្ទះ ឬក៏អាចជាប្រេងម៉ាស៊ីន ឬក៏អាចជាប្រេងផ្សេងៗ
ដែលគាត់ទុកប្រើប្រាស់នៅក្នុងផ្ទះរបស់គាត់ អញ្ចឹងនៅក្នុងថ្នាក់ទី ១ នៃបន្ទប់ដាក់សម្ភារៈ
យើងឃើញមានធុងនិងមានដបថ្នាំ។ ចំណែកឯថ្នាក់ទី ២ យើងឃើញមានអំបោសខ្លី ១
សម្រាប់បោសផ្ទះ និងមានប្រដាប់កើបសំរាម ១ ផងដែរពណ៌ខៀវ
ហើយយើងឃើញនៅក្បែរប្រដាប់កើបសំរាមគឺមានដបថ្នាំ ឬក៏បំពង់ផ្សេងៗសម្រាប់ប្រើប្រាស់ផងដែរ
ចំណែកឯថ្នាក់ទី ៣ នៅក្នុងថ្នាក់ទី ៣ យើងឃើញមានដបថ្នាំ និងកូនចានតូចៗជាច្រើន
សម្រាប់ប្រើប្រាស់ អញ្ចឹងនេះគឺជាបន្ទប់ដាក់សម្ភារៈរបស់គាត់
ដូច្នេះនៅពេលដែលគាត់ត្រូវការប្រើប្រាស់សម្ភារៈផ្សេងៗ ដែលគាត់ប្រើប្រាស់នៅក្នុងផ្ទះ
គាត់អាចមកបន្ទប់ដាក់សម្ភារៈ ដើម្បីយកសម្ភារៈទាំងនោះទៅប្រើប្រាស់បាន។

ដែលបន្ទាប់មកទៀតនៅក្នុងរូបភាពទី ៧ នៅក្នុងរូបភាពទី ៧
បន្ទាប់ពីគាត់ចូលមកដល់បន្ទប់ដាក់សម្ភារៈហើយ យើងឃើញក្មេងប្រុសម្នាក់នោះ
គាត់ក៏បានយកឈើអំបោស ឬក៏អំបោសខ្លី គាត់បានយកអំបោសខ្លីមួយ
ជាមួយនឹងប្រដាប់កើបសំរាម អញ្ចឹងគាត់កំពុងតែកាន់អំបោសខ្លីនិងប្រដាប់កើបសំរាម
នៅក្នុងបន្ទប់ដាក់សម្ភារៈរបស់គាត់ ដោយដៃឆ្វេងរបស់គាត់គឺកាន់ប្រដាប់កើបសំរាម
រីឯដៃស្តាំគាត់កាន់អំបោសខ្លី
អញ្ចឹងគាត់កំពុងតែយកអំបោសខ្លីនិងប្រដាប់កើបសំរាមចេញពីបន្ទប់ដាក់សម្ភារៈរបស់គាត់។

បន្ទាប់មកទៀតរូបភាពទី ៨ នៅក្នុងរូបភាពទី ៨ យើងឃើញថា
បន្ទាប់ពីគាត់យកចូលបន្ទប់ដាក់សម្ភារៈយកអំបោសនិងប្រដាប់កើបសំរាមរួចរាល់ហើយ
អញ្ចឹងគាត់ក៏បានយកអំបោសនិងប្រដាប់កើបសំរាមនោះចូលទៅក្នុងផ្ទះបាយរបស់គាត់
អញ្ចឹងគាត់ចូលទៅក្នុងផ្ទះបាយ ដើម្បីបោសកម្ទេចកម្ទី ក៏ដូចជាបោសអំបែងចាន
ដែលបានធ្លាក់បែកអម្បាញ់មិញ អញ្ចឹងនៅក្នុងរូបភាពទី ៨ នេះ គឺយើងឃើញក្មេងបុរសម្នាក់នោះ
គាត់ក៏បានយកអំបោសមកបោសអំបែងប្រមូល អញ្ចឹងគាត់បានប្រមូលអំបែងឲ្យនៅមួយដុំ។
អញ្ចឹងនៅពេលដែលចានគោមធ្លាក់បែក គឺអំបែងរបស់វាគឺនៅរាយប៉ាយ
អញ្ចឹងវានៅរាយប៉ាយលើពេញឥដ្ឋ ឬក៏ពេញផ្ទៃកម្រាលឥដ្ឋ
ដូច្នេះគាត់ត្រូវយកអំបោសមកប្រមូលវាឲ្យនៅមួយដុំ គឺយើងអត់ប្រើប្រាស់ដៃដើម្បីប្រមូលនោះទេ
ព្រោះប្រសិនបើយើងប្រើប្រាស់ដៃ គឺអំបែងចាន ឬក៏អំបែងកម្ទេចកម្ទីចាននោះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

វាអាចធ្វើឲ្យយើងមុតដៃបាន អញ្ចឹងវាអាចធ្វើឲ្យដៃយើងមុត និងមានរបួស
ឬក៏អាចធ្វើឲ្យយើងហូរឈាម ដូច្នេះយើងអត់ត្រូវប្រើប្រាស់ដៃដើម្បីប្រមូលកម្ទេចកម្ទីអំបែង
ឬក៏កម្ទេចកម្ទីកែវ ឬក៏អំបែងចាននោះទេ ព្រោះវាអាចធ្វើឲ្យយើងមានគ្រោះថ្នាក់
ដូច្នេះយើងត្រូវប្រើប្រាស់អំបោស ដើម្បីបោសប្រមូលវាឲ្យនៅមួយដុំ
បន្ទាប់មកយើងយកប្រដាប់កើបសំរាមដើម្បីកើបកម្ទេចកម្ទី ឬក៏អំបែងនោះយកទៅបោះចោល
ដោយជាក់ស្តែងនៅក្នុងរូបភាពទី ៨ បុរសម្នាក់នោះ គាត់បានយកអំបោស
មកបោសប្រមូលអំបែងចាន និងកម្ទេចកម្ទីចាន ឲ្យនៅមួយដុំ
បន្ទាប់មកគាត់យកប្រដាប់កើបសំរាមរបស់គាត់ យកមកកើបនូវកម្ទេចកម្ទីចាន
ដោយគាត់យកអំបោសបោសកម្ទេចកម្ទីចាន ឬក៏អំបែងចាន ចូលមកក្នុងប្រដាប់កើបសំរាមនោះ។

បន្ទាប់មកទៀតរូបភាពទី ៩ នៅក្នុងរូបភាពទី ៩ យើងឃើញថា
បន្ទាប់ពីគាត់បោសសម្អាតនូវកម្ទេចកម្ទីនិងអំបែងចានរួចរាល់ហើយ
គាត់កើបកម្ទេចកម្ទីចានរបស់គាត់ដាក់ចូលទៅក្នុងប្រដាប់កើបសំរាមរួចរាល់ហើយ
អញ្ចឹងគាត់ក៏បានយកកម្ទេចកម្ទី ឬក៏អំបែងចាននោះ យកមកចាក់ចូលទៅក្នុងធុងសំរាម
អញ្ចឹងអំបែងចាន ឬក៏អំបែងកែវ ឬក៏កម្ទេចកម្ទីដែលបានបែក
គឺយើងអត់ត្រូវបោះចោលផ្តេសផ្តាសនោះទេ
ព្រោះប្រសិនបើយើងបោះចោលផ្តេសផ្តាសពាសវាលពាសកាល អញ្ចឹងអាចធ្វើឲ្យអំបែងនោះ
នៅលើផ្លូវ ឬក៏នៅលើទីធ្លាផ្សេងៗ អញ្ចឹងប្រសិនបើមាននរណាម្នាក់មិនបានប្រុងប្រយ័ត្ន
ប្រសិនបើគាត់អត់បានប្រុងប្រយ័ត្ន គាត់ដើរជាន់អំបែង អញ្ចឹងប្រសិនបើគាត់ដើរជាន់អំបែង
អាចធ្វើឲ្យគាត់មុតជើង ឬក៏នៅពេលដែល[យើង]គាត់មិនប្រយ័ត្ន ប៉ះចំអំបែង
អាចធ្វើឲ្យគាត់មុតដៃបាន អញ្ចឹងអាចធ្វើឲ្យនរណាម្នាក់មានគ្រោះថ្នាក់បាន
នៅពេលដែលគេប៉ះពាល់ទៅអំបែងនោះ។ អញ្ចឹងនៅពេលដែលមានការបែកចាន ឬក៏បែកកែវ
យើងអត់ត្រូវយកអំបែងចានឬក៏អំបែងកែវនោះទៅបោះចោលផ្តេសផ្តាសនោះទេ
គឺយើងត្រូវដាក់ក្នុងធុងសំរាមឲ្យបានត្រឹមត្រូវ គឺយើងត្រូវដាក់ក្នុងថង់
និងចងឲ្យបានត្រឹមត្រូវនៅក្នុងធុងសំរាម ដែលជាក់ស្តែងនៅក្នុងរូបភាពទី ៩ នេះ
បន្ទាប់ពីគាត់បោសប្រមូលកម្ទេចកម្ទីអំបែងចានរួចរាល់ហើយ គាត់ក៏បានយកអំបែងចានទាំងនោះ
មកចាក់ចូលទៅក្នុងធុងសំរាម ដើម្បីឲ្យមានសណ្តាប់ធ្នាប់
គឺគាត់អត់យកចាក់ចោលពាសវាលពាសកាលនៅកន្លែងផ្សេងៗនោះទេ
វាអាចធ្វើឲ្យមានគ្រោះថ្នាក់បាន។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ១០ នៅក្នុងរូបភាពទី ១០ យើងឃើញថា បន្ទាប់ពីគាត់ចាក់អំបែងចានចូលទៅក្នុងធុងសំរាមហើយ គាត់ក៏បានកាន់ប្រដាប់កើបសំរាមជាមួយនឹងអំបោសដើរចូលមកក្នុងបន្ទប់ដាក់សម្ភារៈរបស់គាត់វិញ អញ្ចឹងនៅពេលដែលគាត់ប្រើប្រាស់រួច គាត់តែងតែយកឧបករណ៍ដែលគាត់បានប្រើប្រាស់ មកដាក់នៅកន្លែងដើមវិញ ដែលជាក់ស្ដែង អម្បាញ់មិញ បុរសម្នាក់នោះ គាត់បានយកអំបោសនិងប្រដាប់កើបសំរាមចេញពីបន្ទប់ដាក់សម្ភារៈ ហើយចេញពីថ្នាក់ទី ២ នៃបន្ទប់ដាក់សម្ភារៈ ដូច្នេះគាត់ក៏បានកាន់អំបោសនិងប្រដាប់កើបសំរាមនោះ ចូលមកក្នុងបន្ទប់ដាក់សម្ភារៈរបស់គាត់វិញ ដើម្បីដាក់អំបោស និងប្រដាប់កើបសំរាមនោះ ទៅទីកន្លែងដើមរបស់វាវិញ ព្រោះប្រសិនបើយើងអត់ដាក់នៅកន្លែងដើមទេ នៅពេលដែលយើងត្រូវប្រើប្រាស់លើកក្រោយ គឺវាអាចធ្វើឲ្យយើងពិបាកនឹងរកវា អញ្ចឹងវាអាចធ្វើឲ្យយើងវង្វេងវា ដែលធ្វើឲ្យយើងពិបាករក និងចំណាយពេលយូរនៅក្នុងការ[យក]រករបស់នោះមកប្រើប្រាស់វិញ ដូច្នេះយើងត្រូវយកពីកន្លែងណាដាក់នៅកន្លែងដើមវាវិញ អញ្ចឹងនៅពេលដែលយើងត្រូវការប្រើប្រាស់លើកក្រោយ គឺយើងអត់ពិបាករកនោះទេ គឺគ្រាន់តែយើងមករកនៅកន្លែងរបស់វា គឺយើងឃើញតែម្ដង អញ្ចឹងបុរសម្នាក់នេះ គាត់កំពុងតែយកអំបោស និងប្រដាប់កើបសំរាមរបស់គាត់មកដាក់នៅកន្លែងដើមវិញ នៅក្នុងបន្ទប់ដាក់សំរាម។

បន្ទាប់មកទៀតរូបភាពទី ១១ រូបភាពទី ១១ បន្ទាប់ពីគាត់ដាក់ប្រដាប់កើបសំរាម ជាមួយនឹងអំបោស មកកន្លែងដើមនៅក្នុងបន្ទប់ដាក់សម្ភារៈរបស់គាត់វិញហើយ អញ្ចឹងនៅពេលដែលគាត់យកមកដាក់ទុកវិញហើយ បុរសម្នាក់នោះ គាត់ក៏បានអូសបំពង់បឺតធូលី ចេញពីក្នុងបន្ទប់ដាក់សម្ភារៈរបស់គាត់ម្ដងទៀត អញ្ចឹងនៅពេលដែលគាត់អូសបំពង់បឺតធូលី បានន័យថាគាត់កំពុងតែយកទៅបឺតកម្ទេចកម្ទីដែលនៅសល់ អញ្ចឹងវាអាចនឹងគាត់បោសអត់ស្អាត គាត់គិតថាគាត់បោសអត់ទាន់ស្អាត ដូច្នេះគាត់ត្រូវប្រើប្រាស់ម៉ាស៊ីនបូមធូលី ដើម្បីបូមកម្ទេចកម្ទីដែលគាត់មើលអត់ឃើញបន្ថែមទៀត អញ្ចឹងម៉ាស៊ីនបូមធូលីគឺធំ គឺមានធ្ងន់ អញ្ចឹងគឺយើងលើក អត់ត្រូវលើកនោះទេ គឺយើងពិបាកក្នុងការលើក ដូច្នេះម៉ាស៊ីនបូមធូលីគឺមានតែងតែមានកង់រុញ អញ្ចឹងយើងអាចអូសម៉ាស៊ីនបូមធូលីនោះ ដោយសារតែវាមានកង់ អញ្ចឹងវា[...]រអិល ងាយស្រួលក្នុងការអូស អញ្ចឹងយើងអត់ចាំបាច់លើកនោះទេ ដែលជាក់ស្ដែងនៅក្នុងរូបភាពទី ១១ នេះ គឺបុរសម្នាក់នោះ គាត់បានកាន់បំពង់ ឬក៏ទុយោម៉ាស៊ីនបូមធូលី ហើយអូសវាចេញទៅក្រៅ ដែលយើងឃើញម៉ាស៊ីនបូមធូលីនោះគឺមានពណ៌ខៀវ ហើយមានកង់ចំនួន ២

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ប៉ុន្តែដោយសារតែយើងមើលពីចំហៀង អញ្ចឹងយើងឃើញកង់តែ ១ តែប៉ុណ្ណោះ ប៉ុន្តែជាក់ស្តែងគឺម៉ាស៊ីនបូមធូលីគឺមានកង់ចំនួន ២ ដែលម៉ាស៊ីនបូមធូលីគឺប្រើប្រាស់អគ្គិសនី ដូច្នេះយើងឃើញនៅគូទម៉ាស៊ីនបូមធូលីនោះ ឬនៅខាងក្រោម គឺយើងឃើញមានខ្សែភ្លើងមួយ ខ្សែភ្លើងមួយខ្សែ អញ្ចឹងខ្សែភ្លើងនោះគឺចុងម្ខាងគឺជាប់នឹងម៉ាស៊ីនបូមធូលី រីឯចុងម្ខាងទៀត គឺជាប់ទៅនឹងជញ្ជាំង ឬក៏ឌុយដោត អញ្ចឹងវាជាប់ទៅនឹងព្រីភ្លើងដែលនៅជាប់ជញ្ជាំង ដោយសារតែម៉ាស៊ីនបូមធូលីគឺប្រើប្រាស់អគ្គិសនី ដូច្នេះគឺយើងត្រូវដោតខ្សែភ្លើងជាប់ទៅនឹងព្រីភ្លើង ឬក៏ប្រភពអគ្គិសនីផ្សេងៗ ដើម្បីឲ្យម៉ាស៊ីនបូមធូលីដំណើរការបាន អញ្ចឹងបុរសម្នាក់នេះ គាត់កំពុងតែអូសម៉ាស៊ីនបូមធូលី ដែលដោតជាប់ភ្លើងហើយ អញ្ចឹងគាត់ដោតខ្សែភ្លើងឲ្យហើយ ហើយគាត់អូសម៉ាស៊ីនបូមធូលី ដោយកាន់នូវបំពង់នៃម៉ាស៊ីន បន្ទាប់មកគាត់អូសចេញទៅក្រៅ គាត់អូសចេញទៅក្រៅ ក្រៅបន្ទប់ដាក់សម្ភារៈរបស់គាត់ ដើម្បីទៅបូមធូលីនៅក្នុងផ្ទះបាយ។

បន្ទាប់មកទៀតរូបភាពទី ១២ នៅក្នុងរូបភាពទី ១២ បន្ទាប់ពីគាត់យកម៉ាស៊ីនបូមធូលីរបស់គាត់ ចេញមកខាងក្រៅហើយ គាត់ក៏បានដើរសំដៅ ឬក៏អូសម៉ាស៊ីននោះ សំដៅទៅកាន់ផ្ទះបាយ ទៅកន្លែងដែលមានចានបែកអម្បាញ់មិញ អញ្ចឹងប្រហែលជាគាត់បោសអត់ស្អាត ឬក៏គាត់គិតថាបោសអត់ស្អាត ដោយសារតែ ពេលខ្លះអំបែងចានគឺតូចៗ អញ្ចឹងយើងអត់អាចមើលឃើញនោះទេ ដោយពេលខ្លះអំបោសគឺបោសប្រមូលបានតែអំបែងណាធំៗ អំបែងធំៗ អញ្ចឹងគាត់បោសប្រមូលតែអំបែងធំៗតែប៉ុណ្ណោះ ចំណែកឯអំបែងតូចៗ ឬក៏កម្ទេចកម្ទីតូចៗ ដែលយើងអត់អាចមើលឃើញ គឺយើងអត់អាចបោសប្រមូលបាននោះទេ ដូច្នេះកម្ទេចកម្ទីតូចៗក៏អាចធ្វើឲ្យយើងមានគ្រោះថ្នាក់ដែរ ប្រសិនបើយើងជាន់ទៅលើវា អញ្ចឹងដើម្បីការពារ ឬក៏ដើម្បីបង្ការកុំឲ្យមានគ្រោះថ្នាក់ នៅពេលដែលយើងប៉ះពាល់ទៅដល់អំបែងតូចៗទាំងនោះ គាត់ក៏បានយកម៉ាស៊ីនបូមធូលីទៅបូមកម្ទេចកម្ទីតូចៗ ដែលជាក់ស្តែងនៅក្នុងរូបភាពទី ១២ យើងឃើញគាត់កំពុងតែប្រើប្រាស់ម៉ាស៊ីនបូមធូលីអម្បាញ់មិញ ហើយយកមកបូមកម្ទេចកម្ទីអំបែងចានដែលនៅលើកម្រាលឥដ្ឋបន្ថែមទៀត ដែលយើងឃើញកម្ទេចកម្ទីអំបែងចាននៅលើកម្រាលឥដ្ឋ កំពុងតែស្រូបចូលទៅក្នុងម៉ាស៊ីនបូមធូលី តាមរយៈបំពង់ម៉ាស៊ីន អញ្ចឹងបំពង់ម៉ាស៊ីនបូមធូលីគឺប្រើប្រាស់ខ្យល់បឺតចូល ដោយសារតែវាប្រើប្រាស់អគ្គិសនី អញ្ចឹងវាមានម៉ាស៊ីននោះ និងដំណើរការបឺតខ្យល់ចូលទៅខាងក្នុងម៉ាស៊ីន អញ្ចឹងនៅពេលដែលយើងដាក់ជិតកម្ទេចកម្ទី ឬក៏ដាក់នៅជិតសំរាមផ្សេងៗ សំរាម ឬក៏ធូលី ឬក៏កម្ទេចកម្ទីនោះ នឹងបឺតចូលទៅក្នុងម៉ាស៊ីនខ្លួនឯងតាមខ្យល់ អញ្ចឹងដោយសារតែម៉ាស៊ីនគឺមានខ្យល់ខ្លាំងបឺតចូលក្នុង ដូច្នេះវាអាចបឺតចូលនូវកម្ទេចកម្ទី ក៏ដូចជាធូលីនិងអំបែងតូចៗដែលយើងមើលអត់ឃើញ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដែលយើងបោសអត់ស្អាត ចូលទៅក្នុងម៉ាស៊ីនបានយ៉ាងស្អាត អញ្ចឹងយើង
នៅពេលដែលយើងប្រើប្រាស់ម៉ាស៊ីនបូមធូលី
គឺយើងអត់ចាំបាច់ភ័យព្រួយថាយើងនៅសល់កម្ទេចកម្ទី ឬក៏អំបែងចានទៀតនោះទេ
ដោយសារតែម៉ាស៊ីនបូមធូលីមានខ្យល់ខ្លាំង ដូច្នេះវាអាចបូមកម្ទេចកម្ទីខ្យល់
ឬក៏បូមកម្ទេចកម្ទីអំបែងចានចូលទៅក្នុងម៉ាស៊ីនបាន ដោយយើងមិនចាំបាច់បារម្ភអំពីការមុតជើង
ឬក៏មុតដៃទៀតនោះទេ ព្រោះវាអាចសម្អាតបានស្អាតជាងការបោសសម្អាតដោយប្រើអំបោស។

បន្ទាប់មកទៀតរូបភាពទី ១៣ រូបភាពទី ១៣
បន្ទាប់ពីគាត់ប្រើប្រាស់ម៉ាស៊ីនបូមធូលីនោះរួចរាល់ហើយ អញ្ចឹងបានន័យថាគាត់
ប្រាកដថាគាត់បានសម្អាតនៅក្នុងផ្ទះបាយរបស់គាត់បានស្អាតហើយ
បន្ទាប់ពីគាត់ធ្វើឲ្យបែកចានអម្បាញ់មិញ
ហើយគាត់យកម៉ាស៊ីនបូមធូលីទៅបូមអំបែងចានឲ្យអស់ចេញពីកម្រាលឥដ្ឋ
បន្ទាប់ពីគាត់សម្អាតរួចរាល់ហើយ គាត់ក៏បានចាប់បំពង់ម៉ាស៊ីនបូមធូលីដោយដៃទាំងពីររបស់គាត់
ហើយគាត់បានអូសម៉ាស៊ីនបូមធូលីនោះយកមកទុកនៅកន្លែងដើមវិញ។
អញ្ចឹងនៅពេលដែលគាត់ប្រើប្រាស់ម៉ាស៊ីនបូមធូលី គឺគាត់អត់ចាំបាច់លើកម៉ាស៊ីននោះឡើងលើទេ
អញ្ចឹងគាត់អត់ចាំបាច់លើក ឬក៏យួរម៉ាស៊ីនបូមធូលីនោះទេ ដោយសារតែម៉ាស៊ីនបូមធូលីគឺធ្ងន់
អញ្ចឹងគឺវាមានកង់សម្រាប់រុញ ដូច្នេះដើម្បីប្រើប្រាស់វា គឺយើងគ្រាន់តែរុញ ឬក៏អូសវា
គឺវាអាចទៅមុខបានយ៉ាងស្រួលដោយសារវាមានកង់ អញ្ចឹងយើងអត់ចាំបាច់លើកវានោះទេ
ដែលជាក់ស្តែងនៅក្នុងរូបភាពទី ១៣ គឺបុរសម្នាក់នោះ គាត់កំពុងតែអូសម៉ាស៊ីនបូមធូលី
គាត់កំពុងតែអូសម៉ាស៊ីនបូមធូលីចូលមកក្នុងផ្ទះ ឬក៏ចូលមកក្នុងបន្ទប់ដាក់សម្ភារះរបស់គាត់វិញ
ដោយគាត់ដាក់ម៉ាស៊ីនបូមធូលីទៅកាន់កន្លែងដើមរបស់វា អញ្ចឹងបុរសម្នាក់នេះ
គឺជាមនុស្សដែលមានសណ្តាប់ធ្នាប់ ដូច្នេះគាត់ប្រើប្រាស់របស់
នៅពេលដែលគាត់ប្រើប្រាស់របស់រួចហើយ គាត់តែងតែដាក់របស់នោះចូលទៅក្នុងកន្លែងដើមវាវិញ
ដើម្បីកុំឲ្យពិបាករកនៅពេលដែលគាត់ចង់ប្រើប្រាស់ពេលក្រោយទៀត។

បន្ទាប់មកទៀត ១៤ នៅក្នុងរូបភាពទី ១៤ យើងឃើញថា បន្ទាប់ពីគាត់បោសសម្អាត
និងជូតសម្អាតបូមធូលីចេញពីផ្ទះបាយរបស់គាត់ហើយ គាត់ប្រាកដក្នុងចិត្តថា
ផ្ទះបាយរបស់គាត់ស្អាត មិនមានអំបែងចាន ឬក៏កម្ទេចកម្ទីចានតូចៗនៅនឹងលើកម្រាលឥដ្ឋនោះទេ
ព្រោះតែគាត់ធ្វើបែកចានអម្បាញ់មិញ អញ្ចឹងគាត់បាន ប្រាកដថាគាត់បានសម្អាតស្អាតហើយ
លែងមានអំបែងចានហើយ បុរសម្នាក់នោះគាត់ក៏បានដើរចូលទៅផ្ទះបាយម្តងទៀត
អញ្ចឹងគាត់ក៏បានដើរចូលទៅផ្ទះបាយ ហើយគាត់ក៏បើកទូចានដើម្បីយកចានផ្សេងមកប្រើប្រាស់

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងយើងឃើញផ្ទះបាយរបស់គាត់ គឺមានទូដាក់ចាន គឺមានទូដាក់ចាន
ឬក៏ដាក់សម្ភារៈផ្ទះបាយផ្សេងៗ ដូចជាចានគោម និងចានសំប៉ែតជាដើម
អញ្ចឹងចានគឺយើងត្រូវដាក់ក្នុងទូដើម្បីកុំឲ្យដីហុយប្រឡាក់ ឬក៏ធូលីហុយប្រឡាក់
ដូច្នេះប្រសិនបើយើងដាក់នៅខាងក្រៅធូលីអាចហុយប្រឡាក់ចានរបស់យើង
អញ្ចឹងមុននឹងយើងប្រើប្រាស់យើងត្រូវលាងសិន ប៉ុន្តែប្រសិនបើយើងដាក់នៅក្នុងទូ
ពេលខ្លះគឺអត់មានធូលីហុយប្រឡាក់នោះទេដោយសារតែទូបិទជិត អញ្ចឹងចានរបស់យើងគឺស្អាត។
ដែលយើងឃើញនៅក្នុងរូបភាពនេះ បុរសនោះ គាត់បានលើកដៃទាំងពីររបស់គាត់
ទៅបើកទ្វារទូទាំងសងខាង អញ្ចឹងទូចានរបស់គាត់គឺមានទ្វារសងខាង
ហើយនៅក្នុងទូចានយើងឃើញមានចានគោមជាច្រើន អញ្ចឹងមានចំនួន ២ ថ្នាក់
ទូចានរបស់គាត់មានចំនួន ២ ថ្នាក់ ដែលថ្នាក់នៃទូចានទាំង ២ គឺគាត់សុទ្ធតែដាក់ចានគោមទាំងអស់
ដោយយើងឃើញនៅក្រោមទូចាន គឺមានឡាបូមួយសម្រាប់លាងដៃ ឬក៏លាងចាន
អញ្ចឹងជាទូទៅនៅក្នុងផ្ទះបាយគឺយើងតែងតែមានឡាបូមួយសម្រាប់ធ្វើការលាង ទុកសម្រាប់លាងដៃ
ឬក៏ទុកសម្រាប់លាងចានរបស់យើងនៅពេលដែលយើងប្រើប្រាស់រួច
អញ្ចឹងនៅពេលដែលយើងប្រើប្រាស់ចានរួច យើងត្រូវលាងចាន លាងសម្អាតចាន
ហើយយកទៅទុកនៅក្នុងទូ អញ្ចឹងនៅក្នុង នៅលើឡាបូនេះ យើងឃើញមានក្បាលរ៉ូប៊ីនេទឹកមួយ
សម្រាប់បង្ហូរទឹកចេញ អញ្ចឹងនៅពេលដែលយើងប្រើប្រាស់ទឹកយើងគ្រាន់តែមួលក្បាលរ៉ូប៊ីនេ
នោះទឹកម៉ាស៊ីននឹងហូរចេញតាមបំពង់បង្ហូរទឹក ហើយហូរជាមកចូលទៅក្នុងឡាបូសម្រាប់លាងដៃ
ឬក៏លាងចាន អញ្ចឹងយើងអាចប្រើប្រាស់ទឹកនោះសម្រាប់លាងដៃ លាងចាន
ឬក៏លាងបន្លែរបស់យើងបាន។ អញ្ចឹងរូបភាពទី ១៤ បុរសម្នាក់នោះ គាត់បានដើរមកបើកទូចាន
នៅក្នុងផ្ទះបាយ ដើម្បីយកចានគោមមួយផ្សេងទៀតទៅប្រើប្រាស់។

បន្ទាប់មកទៀតរូបភាពទី ១៥ នៅក្នុងរូបភាពទី ១៥ យើងឃើញថា
បន្ទាប់ពីគាត់យកចានថ្មីមកហើយ អញ្ចឹងបុរសម្នាក់នោះ គាត់ក៏បានយកចានថ្មីមកប្រើប្រាស់
ដោយចានថ្មីរបស់គាត់គឺមានពណ៌បៃតង អញ្ចឹងពេលមុនគាត់ប្រើប្រាស់ចានពណ៌ផ្កាឈូក
ដែលគាត់ធ្វើឲ្យបែក អញ្ចឹងនៅពេលដែលគាត់បោសសម្អាតផ្ទះបាយរបស់គាត់
បោសសម្អាតអំបែងចានរួចរាល់ហើយ គាត់បានបោសសម្អាតអំបែងចានរួចរាល់ហើយ
អញ្ចឹងគាត់ក៏បានយកចានថ្មីមកប្រើប្រាស់ម្តងទៀត ដោយចាននេះគឺគាត់ប្រើប្រាស់ចាន
គាត់ប្រើប្រាស់ចានគោមពណ៌បៃតង អញ្ចឹងម្តងនេះគឺគាត់ប្រុងប្រយ័ត្នជាងមុន
ដោយគាត់យកចានគោមរបស់គាត់ ដោយគាត់កាន់ដៃទាំងពីររបស់គាត់
កាន់ចានគោមដោយដៃទាំងពីរ ហើយយកមកដាក់នៅលើតុនៅក្នុងផ្ទះបាយ ក្បែរបន្លែរបស់គាត់វិញ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងគាត់បានយកចានថ្មីមកដាក់ងាយស្រួលក្នុងការនៅពេលដែលគាត់ចិតបន្លែហើយ
គាត់អាចយកបន្លែទាំងនោះដាក់ទៅក្នុងចានគោម។

បន្ទាប់មកទៀតរូបភាពទី ១៦ នៅក្នុងរូបភាពទី ១៦ បន្ទាប់ពីគាត់សម្អាតផ្ទះបាយរបស់គាត់
និងគាត់យកចានថ្មីមកហើយ បុរសម្នាក់នោះ គាត់ក៏បានបន្តការចិតបន្លែរបស់គាត់បន្តទៀត
អញ្ចឹងយើងឃើញគាត់នៅឈរនៅខាងមុខតុរបស់គាត់ ឈរនៅក្បែរតុ ហើយដៃរបស់គាត់ទាំងពីរ
ក៏ចាប់ផ្តើមកាន់កាំបិត និងកាន់បន្លែដើម្បីចិតបន្លែបន្តទៀត
ប៉ុន្តែលើកនេះគាត់មានការប្រុងប្រយ័ត្នជាងមុន
ដោយគាត់អត់ដាក់ចានគោមថ្មីរបស់គាត់នៅក្បែរដៃរបស់គាត់ទេ
ព្រោះគាត់ខ្លាចនៅពេលដែលគាត់ចិតបន្លែ ដៃរបស់គាត់ធ្វើឲ្យចានគោម ប៉ះចានគោម
ធ្វើឲ្យចានគោមធ្លាក់បែកម្តងទៀត។ អញ្ចឹងគាត់បានដាក់ចានគោមរបស់គាត់នៅឆ្ងាយពីដៃរបស់គាត់
ដោយគាត់ដាក់នៅក្បែរបន្លែរបស់គាត់វិញ ហើយគាត់បន្តការចិតបន្លែរបស់គាត់
ដោយគាត់ហាន់ការ៉ុតជាចំណិតតូចៗ ដោយដៃម្ខាងគាត់កាន់កាំបិត ដៃម្ខាងគាត់កាន់ដើមមើមការ៉ុត
អញ្ចឹងគាត់ហាន់ការ៉ុតជាចំណិតតូចៗសម្រាប់ធ្វើម្ហូប ដែលនៅក្បែរដៃរបស់គាត់ម្ខាងទៀត
គឺយើងឃើញមានបន្លែជាច្រើននៅលើតុ ដូចជាប៉េងប៉ោះ ដូចជាការ៉ុត ដូចជាខ្ទឹមបារាំង
និងដូចជាម្ទេសប្លោកជាដើម។ អញ្ចឹងគាត់កំពុងតែធ្វើម្ហូបនៅក្នុងផ្ទះបាយរបស់គាត់
សម្រាប់អាហារថ្ងៃនេះ សម្រាប់ជាអាហារពេលថ្ងៃត្រង់ ឬក៏សម្រាប់ជាអាហារពេលល្ងាច
ដោយគាត់ចិតបន្លែដែលមានការប្រុងប្រយ័ត្នជាងមុន ព្រោះគាត់ខ្លាចធ្វើឲ្យបែកចានគោមម្តងទៀត
ដោយសារតែពេលមុន ដោយសារតែគាត់ធ្វេសប្រហែស ដូច្នេះធ្វើឲ្យគាត់
ធ្វើឲ្យបែកចានគោមរបស់គាត់។ អញ្ចឹងនៅពេលដែលគាត់ធ្វើឲ្យបែកចានគោម
គាត់ត្រូវតែបោសសម្អាតចានគោម ឬក៏អំបែងចានគោមចេញពីផ្ទះបាយឲ្យស្អាត ដូច្នេះលើកនេះ
គាត់មានការប្រុងប្រយ័ត្នជាងមុន ដោយគាត់ចិតបន្លែដោយមានការប្រុងប្រយ័ត្ន
និងមិនធ្វើឲ្យបែកចានគោមម្តងទៀតនោះទេ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.